/

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមហ៊ុន ស៊ីនឡាន (ខេមបូឌា) ហ្គាមេន ខមេភនី លីមីធីត

XINLAN (CAMBODIA) GARMENT COMPANY LIMITED

រោងចក្រ ភូមិ ព្រៃបឹង សង្កាត់ កន្ទោក ខណ្ឌ ពោធិ៍សែនជ័យ រាជធានីភ្នំពេញ

# កំណត់ហេតុ

## ស្តីពីការព្រមព្រៀងព្យួរកិច្ចសន្យាការងារនិងនិតិវិធីក្នុងការបើកប្រាក់ឈ្នួល

នៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០២០ វេលាម៉ោង ០៩:០០ នាទី មានការបើកអង្គប្រជុំមួយក្រោមអធិបតីលោក YIN JU LIANG ជានាយកក្រុមហ៊ុន និង លោក កង វ៉ាន់ណែត ជាលេខាគត់ត្រាបានបើកអង្គប្រជុំមួយស្តីពីការព្រមព្រៀងព្យួរកិច្ចសន្យាការងារ និងនិតិវិធីក្នុងការបើកប្រាក់ឈ្នួលដែលមានទីតាំងនៅក្រុមហ៊ុន ស៊ីនឡាន (ខេមបូឌា) ហ្គាមេន ខមេភនី លីមីធីត។

សមាសភាពចូលរួមជាភ្ញៀវកិត្តិយសរួមមាន :

-លោក YIN JU LIANG តួនាទីជានាយកក្រុមហ៊ុន

-លោក កង វ៉ាន់ណែត តួនាទី ប្រធានរដ្ឋបាល

-ប្រធានក្រុម និងប្រធានផ្នែក

- តំណាងប្រតិភូបុគ្គលិកពេញសិទ្ធនិងជំនួយទាំងអស់

ជាកិច្ចចាប់ផ្តើមលោក YIN JULIANG ជាប្រធានអង្គប្រជុំបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ ប្រធានក្រុម ប្រធានផ្នែក ព្រមទាំងកម្មករនិយោជិតទាំងអស់ដែលបានចូលរួមក្នុងការសហការនេះ។ ក្នុងនាមលោក ជាប្រធានអង្គប្រជុំក៏បានបញ្ជាក់ផងដែរនូវគោលបំណងនៃកិច្ចប្រជុំ ដោយលោកនាយកបានបញ្ជាក់យ៉ាងច្បាស់លាស់នៃខ្លឹមសារនៃសេចក្តីជូនដំណឹងលេខ ០០៩/២០ កប/ស.ជ.ណ.ខ.ល និងសេចក្តីជូនណែនាំលេខ ០៤៥ កប/ស.ណ.ន.ខ.ល ។ គិតត្រឹមថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០២០ ក្រុមហ៊ុន ស៊ីនឡាន (ខេមបូឌា) ហ្គាមេន ខមេភនី លីមីធីត មានកម្មករនិយោជិតចំនួន ៤២៣ នាក់ ហើយចំនួនកម្មករនិយោជិតដែលនឹងត្រូវដាក់ពាក្យស្នើសុំព្យួរការងារមានចំនួន ៦២នាក់ ក្នុងនោះមានកម្មការិនីចំនួន ៤៧ នាក់ដោយសារតែខ្វះការបញ្ជាទិញពីអតិថិជននៅសហរដ្ឋអាមេរិកនិងប្រទេសផ្សេងៗទៀត។ រយៈពេលនៃការព្យួរ ០២ ខែ ដោយគិតចាប់ពីថ្ងៃទី០១ខែ មិថុនា ដល់ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០២០

-របៀបក្នុងការបើកប្រាក់ឈ្នួល

ក្រោយពីបានធ្វើការណែនាំយ៉ាងច្បាស់លាស់អំពីគោលការណ៍រួចហើយ អង្គប្រជុំបានមូលមតិគ្នាជាឯកឆន្ទកំណត់ការបើកប្រាក់ឈ្នួលចំនួន ៦០ ដុល្លាអាមេរិកនៅថ្ងៃទី៣០ ខែ មិថុនាឆ្នាំ ២០២០ និងថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០២០តាមរយៈធនាគារវីងផ្ញើទៅលេខទូរសព្ទ័ដៃរបស់កម្មករនិយោជិតដែលនឹងត្រូវព្យួរការងារ។

កិច្ចពិភាក្សាការងារបានចប់សព្វគ្រប់នៅថ្ងៃខែឆ្នាំដដែលក្រោមបរិយាកាសសោមនស្សរីករាយ និងស្និទ្ធស្នាលក្រៃលែងជាងទីបំផុត។

ថ្ងៃ អង្គារ ៥កើត ខែ ជេស្ឋ ឆ្នាំ ជូត ទោស័ក ពស ២៥៦៤

Scanned with CamScanner

ភ្នំពេញ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០២០

បានឃើញ និង ឯកភាព

នាយកក្រុមហ៊ុន

WANGYINGFU

លេខាកត់ត្រា

ប្រធានរដ្ឋបាល

Kang Vannet

ហត្ថលេខានិងស្នាមមេដៃប្រតិភូបុគ្គលិក

Scanned with CamScanner